# មជ្ឈមណ្ឌលឯកសារកម្ពុជា

## របាយការណ៍

## ស្តីពីសកម្មភាព និងលទ្ធផលការងារចុះស្រាវជ្រាវធ្វើផែនទីរណ្តៅសាកសព ជនរងគ្រោះដោយពួកខ្មែរក្រហមប្រល័យពូជសាសន៍ នៅទីក្រុងព្រះសីហនុ

កាលពីថ្ងៃទី១៥ ខែកុម្ភៈ គ.ស ២០០០ មជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជាបានចាត់តាំងឲ្យសហការី៣នាក់គឺៈ

១-លោក ផាត កុសល នាយករងទី១មជ្ឈមណ្ឌលឯកសារកម្ពុជា

២-លោក វ៉ាន់ថាន់ ពៅដារ៉ា ប្រធានការិយាល័យនៃមជ្ឈមណ្ឌលស្រាវជ្រាវឯកសារ

៣-លោក ស៊ិន ឃិន ជំនួយការអមទីសតីការគណៈរដ្ឋមន្ត្រី

ក្រុមស្រាវជ្រាវយើងបានទទួលបញ្ជាពីលោកនាយកមជ្ឈមណ្ឌលឯកសារ ឲ្យនាំក្រុមថតខ្សែភាពយន្តឯកសារប្រទេសអ៊ឺរ៉ុបក្នុងនោះមានប៊ែលហ្ស៊ិក (Belgique) បារាំង (France) និង អៀរឡង់ (Erllang) ។ ក្រុមយើងបាននាំពួកទាំងនេះទៅក្រុងព្រះសីហនុ ។

យើងបានធ្វើដំណើរតាមផ្លូវជាតិលេខ៤ កាត់តាមខេត្តកំពង់ស្ពឺ ទៅដល់ក្រុងព្រះសីហនុនៅវេលាម៉ោង១៣ៈ០០ ទទួលទានបាយថ្ងៃត្រង់រួចនៅម៉ោង១៤ៈ០០ យើងបានទៅសុំជួបឯកឧត្តមអភិបាលក្រុងព្រះសីហនុនៅឯសាលាក្រុង ។

ថ្ងៃទី ១៦-០២-២០០០

នៅម៉ោង ១៤ៈ០០ យើងបានជួបឯកឧត្តម ពុត ចាន់រិទ្ធី អភិបាលរងទី២ក្រុងព្រះសីហនុ លោក ស៊ុន សុខន អគ្គលេខាធិការសាលាក្រុង និងលោក សំ សំអាត នាយខុទ្ទកាល័យសាលាក្រុងព្រះសីហនុ ។

បន្ទាប់ពីបានជួបអាជ្ញាធរដែនដី យើងក៏បានខទ្វេសនាមក្រុមស្រាវជ្រាវយើង និងក្រុមថតខ្សែភាពយន្តឯកសារប្រទេសអឺរ៉ុប ហើយយើងក៏បានសុំអនុញ្ញាតឯកឧត្តមអភិបាលរងទី២ក្រុងឲ្យភាគីថតឯកសារចូលថតពេលកំពុងទំនាក់ទំនងការងាររវាងក្រុមយើងនឹងអាជ្ញាធរដែនដី ។ ជាដំបូងយើងជម្រាបឯកឧត្តមអភិបាលក្រុងនិងសហការី អំពីគោលបំណងនិងសំណូមពររបស់យើងដែលចុះមកក្រុងព្រះសីហនុនេះ ខ្លឹមសារដូចយើងចុះបណ្តាខេត្តដទៃដែរ ប៉ុន្តែដោយឡែកឱកាសនេះយើងមាននាំបរទេសមកថតខ្សែភាពយន្តដែរ នេះជាកត្តាពិសេសដោយឡែកពីបណ្តាខេត្តក្រុងនានា ប៉ុន្តែយើងក៏ធ្លាប់បាននាំខ្សែភាពយន្តបារាំងទៅខេត្តកំពង់ធំម្តងរួចហើយ ។

ម្យ៉ាងទៀត ក្រោយពីបានជម្រាបពីបំណងរបស់ក្រុមស្រាវជ្រាវយើងនិងក្រុមថតខ្សែភាពយន្តឯកសាររួចយើងក៏បានសំណូមពរចំពោះលោកអភិបាលក្រុងដូចតទៅះ

- ស្នើសុំចំណារជាលាយលក្ខណ៍អក្សរដ្ឋការមួយ បញ្ជាឲ្យអង្គភាពមួយចំនួនជួយសហការការងារជាមួយក្រុមយើងនិងក្រុមថតខ្សែភាពយន្តឯកសារ ។ អង្គភាពទាំងនោះរួមមានះ

១ - មេបញ្ជាការកងរាជអាវុធហត្ថជាតិ

២ - មេបញ្ជាការស្នងការប៉ូលិសក្រុង

៣ - មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ

៤ - មន្ទីរធម្មការនិងសាសនា

៥ - មន្ទីរពត៌មាននិងខ្សែភាពយន្តក្រុង

៦ - ខណ្ឌព្រៃនប់ៈ ខណ្ឌនេះគោលដៅយើងត្រូវចុះទៅទីតាំងប្រល័យពូជសាសន៍កោះខ្យង ។ ហើយដោយចំណុចទីតាំងកោះខ្យងនោះមានមីន យើងក៏បានស្នើសួររកពួកស៊ីម៉ាក់ ១៩៨៤ ប៉ុន្តែអភិបាលក្រុងថា ក្រុមនេះចំណុះក្រសួងការពារជាតិ យើងក៏បានស្នើលោកនាយកមជ្ឈមណ្ឌលឯកសារទាក់ទងទៅទីក្រុងភ្នំពេញបានសម្រេច លោកក៏នាំចុះទៅថ្ងៃទី ១៨ តែម្តង ។

<u>ពត៌មានអំពីទីតាំងឧក្រិដ្ឋកម្ម គុកសន្តិសុខ ទីតាំងសម្លាប់ និងរណ្តៅសាកសព</u>

ក្រុមយើងក៏បានសាកសួរឯកឧត្តមអភិបាលក្រុងនិងសហការីនៅទូទាំងខណ្ឌចំណុះក្រុងផងដែរអំពីបញ្ហានេះ ប៉ុន្តែអស់លោកទាំងនោះក្តាប់មិនបាន គឺសុទ្ធតែមកក្រុងព្រះសីហនុថ្មីទាំងអស់ ទើបតែបាន១០ខែប៉ុណ្ណោះ ដូចនេះគាត់មិនអាចដឹងអ្វីឡើយ ប៉ុន្តែគាត់បានប្រាប់ឲ្យយើងទៅទាក់ទងបណ្តាមន្ទីរនានាដូចដែលយើងបានសំណូមពរ ដើម្បីទំនាក់ទំនងការងារទាក់ទងនឹងបញ្ហានេះ ។

<u>ម៉ោង ១៥ៈ០០</u>

ក្រុមយើងរួមមានមន្ត្រីក្រុងម្នាក់ផង ហើយនិងក្រុមថតឯកសារក៏បានធ្វើដំណើរមកដល់មន្ទីរពត៌មានក្រុង នៅទីនោះយើងបានជួបះ

១ - លោក កង សារ៉ាន់ ប្រធានមន្ទីរពត៌មានក្រុង

២ - សហការីរបស់គាត់ម្នាក់ យើងមិនបានចាំឈ្មោះ

## Ξ. អំពីពត៌មានទាក់ទងអំពើឧក្រិដ្ឋកម្ម

លោក កង សារ៉ាន់ បានបញ្ជាក់ប្រាប់យើងថា នៅក្រុងព្រះសីហនុ ទីតាំងគុកនិងសន្តិសុខ និងទីតាំងសម្លាប់មានច្រើន ធំជាងបណ្តាទីតាំងផ្សេងៗ គឺនៅកោះខ្យងស្ថិតក្នុងភូមិកោះខ្យងឃុំអូរជ្រៅខណ្ឌព្រៃនប់ ។

ម្យ៉ាងវិញទៀតលោក កង សារ៉ាន់ បានឲ្យយើងទៅទាក់ទងខណ្ឌព្រៃនប់ មេឃុំអូរជ្រៅ និងប្រជាជននៅក្បែរៗទីនោះ ។ គេអាចដឹងជាងគាត់ គាត់គ្មានឯកសារផ្តល់ឲ្យយើងទេដោយហេតុថាពីមុនមន្ទីរពត៌មាននៅជាមួយគ្នានឹងមន្ទីរវប្បធម៌វិចិត្រសិល្បៈ លុះបំបែកចេញក្រោយបោះឆ្នោតគាត់គ្មានឯកសារអ្វីទេ ។ គាត់ឲ្យយើងទៅទាក់ទងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈគេអាចដឹងបានជាងគាត់ ព្រោះប្រធានមន្ទីរទីនោះគាត់ធ្វើការយូរឆ្នាំ ពីឆ្នាំ១៩៧៩ មកទល់ឆ្នាំ ២០០០ ។

<u>ម៉ោង ១៦:០០</u>

ក្រុមយើងបានទៅដល់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈក្រុងព្រះសីហនុ នៅទីនោះយើងបានជួបៈ

១-លោក យុង យុទ្ធី ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ

២-លោក យុន វិសុទ្ធ បុគ្គលិកមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ

## Ξ. <u>អំពីពត៌មានទាក់ទងអំពើឧក្រិដ្ឋកម្ម</u>

មុនស្រង់ពត៌មានប្រយោលពីបណ្តាមន្ត្រីមន្ទីរជំនាញនិងកងសន្តិសុខ យើងបានជម្រាបពីគោលបំណងរបស់យើងនិងក្រុមថតខ្សែភាពយន្តឯកសារ ឲ្យគេយល់ពីការងាររបស់យើងដែលធ្លាប់បានធ្វើតាំងពីឆ្នាំ ១៩៩៥ មកទល់ឆ្នាំ ២០០០ ទិសដៅរបស់យើងចំពោះមុខ និងតទៅមុខទៀត ជាពិសេសពេលកំពុងស្រាវជ្រាវនេះតែម្តង ។

លោក យុង យុទ្ធី បានប្រាប់យើងថា ចំពោះបញ្ហានេះគាត់ធ្លាប់ដឹងដែរ ហើយក៏បានធ្វើខ្លះៗដែរពីមុននោះ ប៉ុន្តែឯកសារគ្មានរក្សាទុកទេ យូរឆ្នាំបាត់បង់អស់ហើយដោយសារការគ្រប់គ្រងផ្ទេរប្តូរផ្លាស់មនុស្ស ប៉ុន្តែគាត់នៅចាំបានថា ទីតាំងគុកសន្តិសុខខ្មែរក្រហម និងកន្លែងសម្លាប់ គាត់បានចាំដឹងដូចជាៈ

១-**ទីតាំងអូរត្រេះ:** កន្លែងសម្លាប់ស្ថិតក្នុងខណ្ឌមិត្តភាពចម្ងាយ៥-៦គីឡូម៉ែត្រពីទីក្រុងព្រះសីហនុ ។

២-**ចម្ការទុរេនៈ** ទីតាំងសម្លាប់ ស្ថិតក្នុងខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ បានដឹងថារណ្តៅសម្លាប់ពី ៥ ទៅ ៦នាក់ គាត់បានឃើញគេគាស់យកមាសថ្គាល់នឹងភ្នែកនាឆ្នាំ១៩៧៩-៨០-៨១ ។

ម្យ៉ាងវិញទៀត ក្រៅពីទីតាំងទាំងអស់នេះគាត់ក៏បានដឹងថាមានទីតាំងធំគឺកោះខ្យង ដូចលោក កង

សារ៉ាន់ ដែរ ទីនោះក្រោយរំដោះ ១៩៧៩ រហូតទល់ ១៩៩៣ យើងមិនអាចទៅទីនោះបានទេ ដូច្នេះគាត់ក៏មិនអាចដឹងច្បាស់ថាយ៉ាងណាៗ នោះទេ ។

ថ្ងៃទី ១៧-០៧-២០០០

ម៉ោង ៨ៈ១០នាទី ក្រុមយើងនិងក្រុមថតភាពយន្តឯកសារបានទៅដល់បញ្ជាការដ្ឋានកងរាជអាវុធហត្ថជាតិ ។

នៅទីនោះយើងបានជួបនឹងលោកវរសេនីយ៍ត្រី ឆៃ នី យើងបានជម្រាបដូចនៅមន្ទីរនានាដែរអំពីបំណងនិងសំណូមពររបស់យើង នៅទីនោះយើងបានសំណូមពរឲ្យកងរាជអាវុធហត្ថជួយរាវមីន និងជួយការពារសន្តិសុខ ។ គាត់ក៏បានប្រាប់យើងថា កងអាវុធហត្ថគ្មានបច្ចេកទេសខាងរាវមីនទេ តែគាត់ធានាជួយការពារសន្តិសុខឲ្យក្រុមយើង ។ លុះវេលាល្ងាចបន្តិច មេបញ្ជាការរបស់គាត់ឲ្យក្រុមយើងចូលជួបម្តងទៀត គាត់មានទស្សនៈទូលំទូលាយ សប្បាយ និងចូលរួមគាំទ្រការស្រាវជ្រាវថតឯកសាររបស់ក្រុមយើង ។ គ្រួសារគាត់រងគ្រោះឪពុកម្តាយបងប្អូនអស់ជាច្រើននាក់ដែរ គាត់ឈឺចាប់ណាស់ចំពោះជនបាតដៃប្រឡាក់ឈាមខ្មែរក្រហមនេះ គាត់សន្យាថានឹងជួយយើងគ្រប់មធ្យោបាយ ។ គាត់ឲ្យអនុសេនីយ៍ទោនាំកម្លាំងមួយរថយន្តរួមមានឈ្មោះដូចខាងក្រោម ដើម្បីការពារយើងថ្ងៃចុះទៅកោះខ្យង៖

១ – កែវ ថា

២ – សុខ រួន

៣ – មាន ម៉ាប់

៤ – ញឹក ម៉ន

៥ – ចក់ ដារ៉ា

៦ – ម៉ម វណ្ណៈ

៧ – សុខ ស៊ុត

ក្រៅពីអស់លោកទាំងនេះ មានលោកអនុសេនីយ៍ទោ.................. កងរាជអាវុធហត្ថជាតិ បាននាំក្រុមយើងតាំងពីថ្ងៃទីមួយអស់រយៈ៤ថ្ងៃជាប់រហូត នេះបញ្ជាក់ថា កម្លាំងកងរាជអាវុធហត្ថបានយកចិត្តទុកដាក់បញ្ហានេះយ៉ាងខ្លាំង ។

ម៉ោង ៩ ខ្វះ ១៥នាទី

ក្រុមយើង និងក្រុមថតខ្សែភាពយន្តឯកសារ បានទៅដល់បញ្ជាការដ្ឋានស្នងការនគរបាលក្រុងព្រះសីហនុ នៅទីនោះយើងបានជួបៈ

១- លោកវរសេនីយ៍ទោ យិន ប៊ុនណា

២- លោកអនុសេនីយ៍ឯក ម៉េន ចន្ថា

៣- លោកអនុសេនីយ៍ទោ ទូច ស៊ីនឿន

យើងបានជម្រាបពីគោលបំណងនិងសំណូមពររបស់យើងនិងក្រុមថតភាពយន្តឯកសារ ព្រមទាំងសំណូមពរឲ្យលោកជួយផ្នែកសន្តិសុខចំពោះក្រុមយើងនៅស្រុក ឃុំ ពេលចុះទៅទីតាំងកោះខ្យង ។ ក្រៅពីនេះយើងក៏ចង់បានពត៌មានសំខាន់ៗនៅទីតាំងប្រល័យពូជសាសន៍ទូទាំងក្រុងព្រះសីហនុ ដែលលោកនិងសហការីបានដឹង ។

Ξ. <u>អំពីពត៌មានទាក់ទងទីតាំងឧក្រិដ្ឋកម្មពួកខ្មែរក្រហម</u>

នៅទីនោះ លោកវរសេនីយ៍ទោ យិន ប៊ុនណាត គាត់បានដឹងច្បាស់ពីទីតាំងគុកសន្តិសុខ និងទីតាំងសម្លាប់នៅកោះខ្យង ទីតាំងនេះគាត់បានដឹង ព្រោះពីមុនគាត់ជានគរបាលនៅខណ្ឌព្រៃនប់នោះ គាត់ទើបផ្លាស់ផ្ទេរមកស្នងការនគរបាលក្រុង ។ ក្រៅពីទីតាំងកោះខ្យង គាត់បានដឹងកន្លែងខ្លះទៀតដូចជាៈ

១-ទីតាំងអន្លង់ធំ ឃុំខកញ៉ា ហេង ចម្ការទុរេន

២-វ៉ាក្រហម សន្តិសុខខ្មែរក្រហម

ក្រៅពីប្រាប់ទីតាំងសំខាន់ៗដូចជាកោះខ្យង យើងបារម្ភថាកោះខ្យងមានមីន គាត់ក៏បង្ហាញផែនទីក្រុងព្រះសីហនុ ពិសេសគឺទីតាំងកោះខ្យងតែម្តង ។ កោះខ្យងគ្មានមីនទេ ព្រោះប្រជាជនរស់នៅពេញទាំងអស់ ឯកន្លែងមានមីនគឺវាលរមាសងាប់ ទីតាំងនេះពួកខ្មែរក្រហមយកជនរងគ្រោះទៅសម្លាប់ច្រើនណាស់ ទីនោះយើងមិនអាចទៅបានទេ ។ ទីតាំងមួយទៀតមានមីនដែរ គឺទីតាំងអណ្តូងទឹក ទីតាំងនេះពីមុនខ្មែរក្រហមការពារយកទឹកដឹក គ្មាននរណាទៅបានទេ មីនដង និងបាញ់ប្រហារផង ។ ប៉ុន្តែទីនោះគឺឆ្ងាយទៅត្រើយខាងនាយទាំងអស់ ។ ឯកោះខ្យងគ្មានមីនទេ ។ យើងមិនអាចស្មានថាអស់មីនទេ ព្រោះនៅកោះខ្យងមានប្រជារាស្ត្រជុះមីនដាច់ដៃដាច់ជើងខ្លះៗហើយ ដូច្នេះយើងនៅតែទាក់ទងរកក្រុមបោសសម្អាតមីនទៅជួយយើងទៀត ព្រោះមានបរទេសទៅជាមួយយើងដែរយើងត្រូវប្រយ័ត្នជានិច្ច ។

ម្យ៉ាងវិញទៀត លោកវរសេនីយ៍ឯកគាត់បានដឹងថា កូនចៅគាត់២នាក់ជាជនរងគ្រោះក្នុងសម័យខ្មែរក្រហម គាត់ឲ្យគេហៅមកជួបយើង ។ អស់លោកទាំងនោះរួចមានៈ

១-លោកអនុសេនីយ៍ឯក ម៉េន ចន្ថា

២-លោកអនុសេនីយ៍ទោ ទូច ស៊ីនឿន

លោកអនុសេនីយ៍ឯក ម៉េន ចន្ថា ជាប់គុកនៅស្រុក១៨ ខេត្តតាកែវឯណោះទេ គាត់ទទួលទារុណកម្មមានស្លាកស្នាមនៅកជើង ពេលជាប់គុកពួកខ្មែរក្រហមដាក់ខ្នោះជើងរលួយស្អុយ ប៉ុន្តែបានជិនាញការចិនដឹកទឹកកកឃើញដើរតាមផ្លូវ ក៏បោះថ្នាំប៉េនីស៊ីលីនឲ្យ២ដបយកមកលាបបានជារហូត ប៉ុន្តែនៅស្លាកស្នាមដល់សព្វថ្ងៃ ។

លោកអនុសេនីយ៍ទោ ទូច ស៊ីនឿន ជាជនរងគ្រោះធ្លាប់ជាប់គុកនៅសន្តិសុខគុកកោះខ្យងរយៈពេល ១៣ខែ (១ឆ្នាំ១ខែ) ទើបរួច អ្នកធ្លាប់ជាប់គុកជាមួយគាត់ គាត់ដឹងថាអគារមួយនោះ១៨៣នាក់ លុះក្រោយមកនៅសល់ពី៩នាក់ទៅ១៣នាក់ ហើយគាត់បានដឹងថាអ្នកណារស់នៅទីណាៗ ហើយគាត់សន្យានាំក្រុមយើងទៅជួបជនរងគ្រោះទាំងនោះ ។

ដោយយល់ឃើញថាលោកអនុសេនីយ៍ទោ ទូច ស៊ីនឿន ជាជនរងគ្រោះធ្លាប់ជាប់គុកនៅកោះខ្យង ហើយគាត់ស្គាល់ជនរងគ្រោះសំខាន់ៗខ្លះទៀតដែលនៅរស់ យើងសម្រេចថាសំណូមពរឲ្យគាត់ជួយយើងរយៈពេល៣ថ្ងៃក្នុងការស្រាវជ្រាវនេះ ។

យើងបានសម្ភាសលោក ស៊ីនឿន មុនសាក្សីដទៃៗទៀត ក្រោយពីយើងឲ្យគាត់ជូនយើងទៅជួបសាក្សីផ្សេងទៀតចំនួន១០នាក់ ហើយម្នាក់ជានាយកសាលាជាជនរងគ្រោះដែរ តែយើងមិនបានសម្ភាសដោយគ្មានពេលវេលា ។

តាមរយៈសាក្សីទី១ លោក ទូច ស៊ីនឿន គាត់បានឲ្យយើងដឹងថា ជនរងគ្រោះមួយចំនួនទៀតដែលធ្លាប់ជាប់គុកជាមួយគាត់ហើយមានជីវិតរស់នៅ មានដូចខាងក្រោមនេះ៖

១-តា សុខ ពីរនាក់ឪនិងកូននៅស្រែអំបិល

២-លោកតា ឥន្ទ ឌីន នៅស្រុកព្រៃនប់

៣-លោកតា គាំ យោ នៅឃុំអណ្តូងថ្ម ស្រុកព្រៃនប់

៤-លោក ប៉ាក សំឌិន នៅស្រុកព្រៃនប់

៥-លោកគ្រូ សែម នៅសាលារៀនទួលទទឹង

៦-លោកគ្រូ ខែម នាយកវិទ្យាល័យព្រះសីហនុ

៧-លោក ឡេង យ៉ាន នៅឃុំអូរជ្រៅ

៨-លោកគ្រូ ចៅ សុខុម នៅភ្នំពេញ

លោក ទូច ស៊ីនឿន ប្រាប់យើងថា មានមួយចំនួនទៀតមិនចាំឈ្មោះ ។ ក្រោយពីដឹងថាជនរងគ្រោះទាំងអស់នៅរស់ និងដឹងទីកន្លែងស្នាក់នៅរបស់គាត់ទាំងអស់ យើងក៏បានកំណត់ពេលវេលាទៅជួបគាត់ជាមុន រួចហើយកំណត់ថ្ងៃ ម៉ោង ជួបគាត់ជាលើកទី២ ដើម្បីកុំឲ្យគាត់ទៅទីណាផ្សេងទៀតនាំឲ្យយើងពិបាកតាមរកគាត់ ។

<u>ម៉ោង ១១ ខ្ទះ ១៥នាទី</u> យើងស្រូតទៅជួបលោកអភិបាលខណ្ឌព្រៃនប់ឈ្មោះ មាស វុធី

-កងរាជអាវុធហត្ថ លោកអនុសេនីយ៍ទោ យិន ឈន

-ប៉ូលិសក្រុងព្រះសីហនុ លេកអនុសេនីយ៍ទោ ទូច ស៊ីនឿន

លោកទាំងពីររួមដំណើរជាមួយយើងមកជួបលោកអភិបាលខណ្ឌព្រៃនប់ ។ ឯខាងខណ្ឌមានលោកអភិបាលខណ្ឌនិងសហការីម្នាក់ទៀត ក្រៅពីនោះមានប៉ូលិសនិងកងរាជអាវុធហត្ថម្នាក់ដែលយើងមិនបានកត់ត្រាឈ្មោះ បានមករួមពិភាក្សាជាមួយយើងដែរ ។

<u>ម៉ោង ១៤:០០</u>

ថ្ងៃទី ១៧-២-២០០០ ក្រោយពីបានជួបលោកអភិបាលខណ្ឌព្រៃនប់រួច លោកអភិបាលខណ្ឌបានជូនដំណឹង ទៅមេឃុំអូរជ្រៅឲ្យត្រៀមរកសាក្សីចាំជួបក្រុមយើង ។ នៅវេលាល្ងាចនេះយើងបានដើររកជួបសាក្សីនៅតាមផ្ទះផ្ទាល់ ដើម្បីសម្រួលស្មារតីកុំឲ្យគាត់តក់ស្លុតភ័យខ្លាច យើងបានប្រាប់គាត់ឲ្យដឹងពីបំណងរបស់ក្រុមយើងនិងក្រុមថតខ្សែភាពយន្តឯកសារ ហើយកំណត់ពេលវេលាថ្ងៃទី ១៨-២-២០០០ ម៉ោង១០ព្រឹកជួបជុំគ្នា រួចយើងឲ្យសាក្សីទាំងអស់ឡើងរថយន្តទៅជាមួយយើងទៅទីតាំងគុក សន្តិសុខនិងកន្លែងសម្លាប់នៅកោះខ្យង ។

<u>ម៉ោង ១៥:០០</u>

យើងបានធ្វើដំណើរឆ្ពោះទៅទីតាំងសាលាឃុំអូរជ្រៅ តាមផ្លូវលំមួយពីភ្នំពេញ បត់ឆ្វេងដៃត្រង់ព្រំប្រទល់សួនឧទ្យានសម្តេចព្រះនរោត្តមសីហនុ ឆ្ពោះទៅត្បូងចម្ងាយពី ៥ ទៅ ៦គីឡូម៉ែត្រ ។

នៅសាលាឃុំអូរជ្រៅ ខណ្ឌព្រៃនប់

នៅទីនោះលោកមេឃុំ សហការី និងប៉ូលិសប្រចាំប៉ុស្តិ៍រដ្ឋបាលឃុំមានឈ្មោះដូចតទៅនេះ ចាំទទួលធ្វើការងារជាមួយយើង៖

១-លោក ប៉ាន ដូត ចៅសង្កាត់ទី១ សង្កាត់អូរជ្រៅ

២-លោក យក់ ឆេង ចៅសង្កាត់ទី២ សង្កាត់អូរជ្រៅ

៣-លោកអនុសេនីយ៍ត្រី បេង នន់ នគរបាលប្រចាំប៉ុស្តិ៍ឃុំអូរជ្រៅ

៤-លោកព្រិន្ទបាលឯក ប៊ូ ម៉ាល់ នគរបាលប្រចាំប៉ុស្តិ៍អូរជ្រៅ

៥-លោកព្រិន្ទបាលឯក សុខ សំអុល នគរបាលប្រចាំប៉ុស្តិ៍ឃុំអូរជ្រៅ

អំពីពត៌មានដែលចៅសង្កាត់បានប្រាប់ក្រុមយើង ក្រោយពីបានបង្ហាញនូវគោលការណ៍លិខិតខទ្ទេសនាមរបស់យើង ពិសេសចំណាររបស់អភិបាលខណ្ឌព្រៃនប់រួចមក លោកចៅសង្កាត់បានឲ្យយើងដឹងថាៈ

នៅឃុំអូជ្រៅមានទីតាំងសម្លាប់ គុកសន្តិសុខខ្មែរក្រហមពិតប្រាកដមែន ស្ថិតក្នុងភូមិកោះខ្យង ឃុំអូរជ្រៅ ។ គុកសន្តិសុខនេះមានទំហំធំធេងណាស់ អាចប្រៀបថា មានសម្លាប់ដូចជើងឯកដែរ ហើយជាគុកសន្តិសុខកងពល ព្រោះនៅទីនោះពីមុនពួកទ័ពខ្មែរក្រហមនៅជុំវិញទាំងអស់ ។ គាត់ប្រាប់យើងថា ចង់ដឹងពត៌មានច្បាស់ថែមទៀត ត្រូវទៅជួបលោកមេភូមិឈ្មោះ ហុង អ៊ន គាត់នៅទីនោះតាំងពីឆ្នាំ១៩៧៩ ។ ពត៌មានលម្អិតឯកសារគ្មាន គាត់មិនសូវដឹងច្បាស់ដែរ ។

នៅឱកាសនោះយើងបានសំណូមពរឲ្យលោកមេឃុំជួយរកសាក្សីជាជនរងគ្រោះ ឬជនដៃដល់ណាដែលធ្លាប់ជាប់គុក និងធ្លាប់សម្លាប់ ឬគ្រប់គ្រងគុកសន្តិសុខកោះខ្យង និងអដ្ឋិធាតុជនរងគ្រោះ ។ គាត់បានប្រាប់យើងថា អដ្ឋិធាតុ ព្រះសង្ឃអាចារ្យបានគាស់រើសយកមកខ្លះៗដែរ ប៉ុន្តែដុតចោលអស់ហើយ ។

នៅម៉ោង ១៥ៈ៣៥នាទី យើងបានត្រឡប់ពីសាលាឃុំអូរជ្រៅ ប៉ុន្តែយើងបានសន្យាថាឲ្យលោកមេឃុំ ព្រមទាំងសាក្សីផង ចាំជួបយើងនៅម៉ោង ៨ៈ០០ ឬ ៩ៈ០០ ។ ព្រឹកថ្ងៃទី ១៨-២-២០០០ ក្រុមយើងមកដល់សាលាឃុំ រួចរួមដំណើរជាមួយលោកមេឃុំនិងសហការី ប៉ូលិសប៉ុស្តិ៍ ទៅជាមួយគ្នា ។

ម៉ោង ១៧ ខ្វះ ១៥នាទី

លោក ផាត កុសល នាយករងទី១មជ្ឈមណ្ឌលឯកសារ និងក្រុងស្រាវជ្រាវយើងបានធ្វើការសម្ភាសន៍ជាមួយក្រុមថតឯកសារនៅសណ្ឋាគារលួនហេង ទីក្រុងព្រះសីហនុ ចាប់ពីម៉ោង ១៥ ខ្វះ ១៥នាទី ដល់ម៉ោង ១៧ៈ៤០នាទី ទើបចប់សំណួរជាភាសាអង់គ្លេស ។ លោក ផាត កុសល ឆ្លើយជាភាសា

អង់គ្លេស ឯក្រុមថតខ្សែភាពយន្តឯកសារគេថតម្នាក់ ឯម្នាក់ទៀតជាអ្នកបច្ចេកទេសសំឡេង ។ បញ្ហាបច្ចេកទេសថត ម្នាក់ទៀតជាអ្នកសួរ គឺពួកគេថតគ្រប់សកម្មភាពរបស់យើងក្នុងការទំនាក់ទំនងការងារជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ។

<u>*ថ្ងៃទី ១៨-២-២០០០*</u>

*ព្រឹកថ្ងៃទី ១៨-២-២០០០ យើងបានចេញដំណើរស្រូតពីព្រលឹមមកកាន់ស្រុកព្រៃនប់ ពិសេសភូមិថ្មី ឃុំថ្មី និងភូមិព្រៃនប់ ឃុំព្រៃនប់ ប្រយោជន៍ដើម្បីសម្ភាសសាក្សីឲ្យបាន២-៣នាក់ មុននឹងទៅទីតាំងកោះខ្យង ព្រោះយើងបានណាត់ម៉ោង១១ព្រឹករង់ចាំក្រុមស៊ីម៉ាក់ទៅពីភ្នំពេញ យើងរួមទៅជាមួយគ្នាតែម្តង ។*

Ξ. <u>***សម្ភាសន៍សាក្សីទី១ៈ***</u> *លោក ទូច ស៊ីនឿន បច្ចុប្បន្នស្នងការនគរបាលក្រុង សម័យ ប៉ុល ពត ជាជនរងគ្រោះធ្លាប់ជាប់គុកនៅគុកកោះខ្យងរយៈពេល១៣ខែ ។ ទូច ស៊ីនឿន អាយុ ៤២ឆ្នាំ កើតនៅភូមិអូរចម្ការ ឃុំសំរុង ស្រុកព្រៃនប់ មុនសម័យ លន់ នល់ ជាសិស្សវិទ្យាល័យព្រះសីហនុ ប្រឡងឌីប្លូមជាប់នៅឆ្នាំ១៩៧៥ ។ គឺប្រឡងជាប់បាន៣ខែខ្មែរក្រហមចូលស្រុក ។ ក្នុងសម័យ ប៉ុល ពត រស់នៅភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ខណ្ឌព្រៃនប់ ជាយុវជនចាប់ពីអាយុ១៥-១៦-១៧-១៨ឆ្នាំ ជាកងពិសេសពួក ប៉ុល ពត (កងចល័ត) ។ គាត់ជាប់គុកពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតចុងឆ្នាំ១៩៧៨ រយៈពេល៣ខែ ។ មូលហេតុជាប់ដោយសារដំឡូងមីមួយមើម មិត្តភក្តិជាកងចល័តដូចគ្នាដេកជាប់គ្នាឈ្មោះ អាគៀន វាលួចដំឡូងស៊ី វាបានឲ្យដំឡូងគាត់១មើម គាត់លាក់ទុកក្រោមក្បាលដំណេក លុះពេលគេចាប់ អាគៀន ជាមិត្តគាត់ពួកខ្មែរក្រហមដែលគ្រប់គ្រងកងចល័តមកឆែកឆេរក្បាលដំណេកគាត់ ឃើញដំឡូងក៏ចាប់គាត់ចងដៃទៅក្រោយរួចហើយបញ្ជូនគាត់ទៅគុកខ្យងតែម្តងទៅ ដោយគ្មានការអប់រំម្តងជាពីរដងអ្វីឡើយ ។*

Ξ. <u>*សកម្មភាពពេលទៅដល់ទីតាំងគុកកោះខ្យង*</u>

*ដំបូងពេលទៅដល់គេគ្មានសួរនាំអ្វីទេ គេដាក់ចូលគុក ដាក់ខ្នោះជើង ដាក់ច្រវាក់ជើង ឯដៃចងទៅក្រោយជា៣ដំណាក់ៈ កែងដៃ មេដៃទាំងពីរ និងកដៃ ។ នៅគុកទី១នេះជាគុកធំ កន្លែងសួរចម្លើយដំបូងបំផុត លុះក្រោយមកបញ្ជូនទៅគុកមួយកន្លែងទៀតគឺគុករៀនសូត្រ កែប្រែ កន្លែងលត់ដំការងារ ។ បញ្ជាក់ពីសាក្សីបន្ថែមថា គុកពួកវាគឺឲ្យជនរងគ្រោះដេកផ្ទាល់ដី បត់ជើងតូចធំ ហូបបបរ គឺនៅទាំងខ្នោះជើងដៃមិនស្រាយចំណងទេ ពួកវាដាក់បបរមួយចានលើដៃទាំងពីររួចវាដួសបបរឲ្យជនរងគ្រោះដទៃ ។ ដួសបបរឲ្យអ្នកចុងក្រោយរួចហើយវាត្រឡប់មកឆក់យកចានពីជនរងគ្រោះទី១វិញ ស៊ីទាន់ឬមិនទាន់គឺវាឆក់យកទាំងបន្ទុំ ដូច្នេះទាមទារហូបបបរឲ្យបានឆាប់ជាទីបំផុត បើមិនដូច្នេះទេពួកវាយកទៅវិញ ជួនពេលខ្លះខ្លាយ*

អស់ពាក់កណ្ដាលក៏មានដែរ ។ សាក្សី ស៊ីនឿន បញ្ជាក់ថា បត់ជើងធំតូចកាយដីខ្សាច់ រួចហើយដេកពីលើលាមកនោះ ជនរងគ្រោះវេទនាណាស់ ដង្កូវស៊ីលាមកវារវរគើមឡើងលើខ្លួនជនរងគ្រោះម្នាក់ៗ ។ រយៈពេល៧ថ្ងៃពួកវាសួរចម្លើយម្ដង ពេលសួរចម្លើយពួកវាវាយសន្លប់ម្នាក់ៗ ជួនកាលងាប់តែម្ដង ។ ដូច្នេះមួយថ្ងៃអាចងាប់ពី៥ទៅ៦នាក់ ដោយជំងឺ អត់អាហារ និងដោយការសួរចម្លើយ ។ អ្នកជាប់គុកជាប់ជាជួរៗ បើម្នាក់ឡើងបត់ជើងតូច-ធំ អ្នកឯទៀតក៏ឡើងដែរទើបអាចឡើងបាន ។ គាត់ថាវេទនាណាស់គាត់មិនសង្ឃឹមថារស់ទេ ។

-ករណី ទូច ស៊ីនឿន បញ្ជាក់ប្រាប់យើងទៀតថា គាត់បានឃើញគេសួរចម្លើយមុនគាត់ពីរនាក់ ។ គេសួរថា អែ្ហងមានទោសអីបានជាជាប់គុក? មិនដឹង! ពួកវាវ៉ៃៈ ម៉េចមិនដឹង? ជនរងគ្រោះឆ្លើយថាខ្ញុំអត់ដឹងអីទេ អត់លួចទេ ឬថា ទើបលួចម្ដងទេ! ពួកវាវាយសំពងយ៉ាងខ្លាំងៈ លួចម្ដងម៉េចក៏មកទីនេះ? មិនមែនទេ អែ្ហងលួចច្រើនដងណាស់ ។ ជនរងគ្រោះឆ្លើយៈ អត់ទេ ខ្ញុំលួចតែម្ដងទេ ពួកវាវាយទាល់តែងាប់ ។ ឯអ្នកទី២មុនគាត់ក៏ដូច្នេះដែរ ឆ្លើយថាលួចតែម្ដងឬ២ដង ត្រូវពួកវាវ៉ៃដូចអ្នកទី១ដែរ ពួកខ្មែរក្រហមវ៉ៃសន្លប់...។ សាក្សី ស៊ីនឿន គាត់គិតថា បើដល់គេសួរអញ បើសិនមិនឆ្លើយថាលួចច្រើនដង ត្រង់នេះត្រង់នោះទេ វាវ៉ៃងាប់ ដូច្នេះគាត់គិតថា ពេលគេសួរឆ្លើយថាលួចច្រើនដង បើងាប់ក៏ងាប់ចុះ កុំឲ្យគេវ៉ៃច្រើនលើក ។ ពួកខ្មែរក្រហមបានហៅគាត់សួរថា អែ្ហងមានរឿងអី? គាត់ (ស៊ីនឿន) ឆ្លើយថា ខ្ញុំលួចដំឡូងស៊ី វាឃ្លានពេក ។ សួរថាលួចប៉ុន្មានដង? ស៊ីនឿន ឆ្លើយថា លួចច្រើនដងណាស់ខ្ញុំចាំមិនអស់ទេ ចម្ការនេះ កន្លែងនោះ ។ល។ ពួកពេជ្ឈឃាតក៏លាន់មាត់ថា អើ! បើឯងឆ្លើយអ៊ីចឹងនេះបានជាជនបដិវត្តន៍ស្មោះត្រង់នឹងអង្គការ អង្គការរកតែអ្នកស្មោះត្រង់ទេតើ ។

-ម្យ៉ាងវិញទៀតយើងបានសម្ភាសសន៍ ស៊ីនឿន បន្តទៀត តើលោកឃើញថាមានគុកប៉ុន្មានអគារ? ហើយជនរងគ្រោះយកមកពីណាខ្លះ? រាល់ថ្ងៃមានឃើញទេនាំជនរងគ្រោះទៅសម្លាប់ឬទេ? គាត់(ស៊ីនឿន) ថា អគារគុកមាន៨កន្លែង គុកធ្ងន់គឺគុកទី១ ឯបីកន្លែងទៀតគុកដែរ ។ ពេលយប់ជាប់ខ្នោះដៃជើង ពេលថ្ងៃបណ្ដើរឲ្យធ្វើការងារ ។ អគារគុកជញ្ជាំងស័ង្កសី ដំបូលស័ង្កសី ប៉ុន្ដែជនរងគ្រោះដេកផ្ទាល់លើដីជាជួរៗ ក្នុងមួយជួរៗមាន៥ទៅ៦នាក់ សុទ្ធតែជាប់ខ្នោះដៃជើងដូចៗគ្នាទាំងអស់ ។

-ប្រភេទជនរងគ្រោះនៅទីនោះ ស៊ីនឿន បានប្រាប់យើងថា អ្នកជាប់នៅទីនោះគឺមកពីគ្រប់ទិសទីពីស្រែអំបិល ពីក្រុងព្រះសីហនុ កោះកុង ហើយគាត់បានឃើញពូរបស់គាត់និងគ្រូបង្រៀនរបស់គាត់ជាប់នៅទីនោះទាំងអស់គ្នា ។ មួយរយៈក្រោយមកគេបានសួរថា អាណាមួយឈ្មោះ ស៊ីនឿន? គាត់ឆ្លើយថាខ្ញុំ ។ អើ! បើដូច្នេះឯងចេញមក ។ វាឲ្យគ្នាវាចាក់សោដោះប្រវាក់ខ្នោះដៃជើង រួចឲ្យចេញ ។ ស៊ីនឿន ថាគាត់

ដើរមិនរួច គាត់វារ លូន ពួកពេជ្ឈឃាតឲ្យដើមដំឡូងមួយដើម គាត់ក៏យកមកធ្វើឈើច្រត់ដើរតិចៗ គាត់បានដើរទៅកន្លែងមួយផ្សេងទៀត ជាមួយជនរងគ្រោះដទៃ ទៅគុកទី២ ។ គុកទី២ធូរស្រាលបន្តិច ធូរត្រង់ថាបញ្ចេញពេលថ្ងៃឲ្យធ្វើការ ពេលយប់ដាក់ខ្នោះដៃជើងវិញ ។ ពួកវាចាត់ឲ្យគាត់ធ្វើបង្គីមួយថ្ងៃឲ្យបាន៦ គឺ៣គូ ។ គាត់ធ្វើទាំងថ្ងៃទាំងយប់ ដល់ម៉ោង១០-១១យប់ទើបហើយ ។ ក្រោយមកទៀតគេឲ្យគាត់ដាំដំឡូង ដំឡូងពួកវាគាស់ចោលពេញចម្ការ ប៉ុន្តែបើជនរងគ្រោះរើសស៊ីពួកវាចេញពីព្រៃមកវៃសំពងដួនវៃផាប់ក៏មានដែរ ។ ម្យ៉ាងទៀត បើជនរងគ្រោះណាណាធ្វើការហត់ហេវ សម្រាកឱបដងចប ឈរឬអង្គុយ ស្រាប់តែពួកឃាតករចេញមកពីព្រៃវៃតែម្តង មិនដឹងគេពួននៅទីណាទេ ។ ក្រោយមកទៀតពួកវាឲ្យ ស៊ីនឿន ដើររកក្តាម លូកក្តាម យកមកឲ្យអ្នកទោសស៊ីរាល់ថ្ងៃ រហូតគាត់គិតថាអ្នកបណ្តើរគាត់តែម្នាក់ទេ វាដេកលក់ គាត់គិតថាប្រុងវៃវាយកកាំភ្លើង ប៉ុន្តែមិនអាចវៃឈ្នះ ព្រោះគាត់គ្មានកម្លាំងសោះ ស្គមពេក គាត់ចេះតែស៊ូទ្រាំការងារ ទ្រាំអត់ឃ្លាន រហូតទាល់តែចុងបំផុតវៀតណាមវាយចូលកម្ពុជាឆ្នាំ១៩៧៨ ដើមឆ្នាំ១៩៧៩ ពួកវាបានដកអ្នកយាមទៅទប់ទល់កងទ័ពទាំងអស់ ដូច្នេះវាក៏យកត្រាក់ទ័រដឹកជនរងគ្រោះក្នុងគុកថយមកនៅគុកតានៃវិញ ។ ពួកគាត់នៅសល់ជីវិតរស់ប្រហែល១៣នាក់ក្នុងចំណោម១៨៣នាក់ ដែលគាត់បានដឹងថាជាប់គុក ជាមួយគ្នា១៨៣នាក់នេះ ។ ប៉ុន្តែក្រៅពី១៣នាក់នេះគឺស្លាប់ទាំងអស់ ដោយវាសម្លាប់មួយយប់ៗ ឬមួយថ្ងៃពី៤ទៅ៥នាក់ ។

<u>ដូច្នេះមូលហេតុ</u>: ជនរងគ្រោះជាសាក្សីបានរួចរស់ជីវិតដោយសារពួកវាបានដោះលែងចុងក្រោយបំផុតឲ្យទៅរកគ្រួសារនៅតាមសហករណ៍វិញ ពេលនោះសភាពការប្រឈមមុខទ័ពវៀតណាមវាចូលកម្ពុជានាឆ្នាំ១៩៧៨ ។ លោក ស៊ីនឿន បញ្ជាក់ចុងក្រោយថា គាត់ហួសចិត្តលែងនិយាយចេញហើយចំពោះពួកខ្មែរក្រហម គាត់សម្រក់ទឹកភ្នែកពេលនឹងឃើញរឿងចាស់ ។

**(សម្តីសាក្សី ស៊ីនឿន លម្អិតមានថតជាកាសែ្សតទុកជាឯកសាររួចហើយ**
**ការកត់ត្រាបានប៉ុណ្ណឹងមិនអស់ទេ) ។**

<u>សាក្សីទី៧</u>

លោក ប៉ាក សំឌិន អាយុ៤៨ឆ្នាំ បច្ចុប្បន្ននៅភូមិព្រៃនប់ ឃុំព្រៃនប់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ សម័យសីហនុជាកុមារ ។ សម័យ លន់ នល់ ជាសិស្ស ។ សម័យ ប៉ុល ពត រស់នៅភូមិឃុំស្រុកដូចខាងលើ ។ សាក្សីនេះជាជនរងគ្រោះធ្លាប់ជាប់គុក១៣ខែនៅទីតាំគុកសន្តិសុខកោះខ្យងដូច ស៊ីនឿន ដែរ ។ ក្រុមយើងបានសម្ភាសន៍ ឲ្យគាត់ប្រាប់យើងអំពីសកម្មភាពពួកខ្មែរក្រហម ជាប់គុកដោយមូលហេតុអ្វី?

រួចពីគុកដោយមូលហេតុអ្វី? ពួកខ្មែរក្រហមធ្វើទារុណកម្មយ៉ាងម៉េចខ្លះមកលើរូបគាត់? គាត់បានឃើញអ្វីខ្លះពេលជាប់គុក? ជនរងគ្រោះនេះធ្លាប់ស៊ីថ្មើមមនុស្ស ដោយហេតុថាពួកវាឲ្យស៊ី គាត់ឃ្លានពេកក៏ស៊ីទៅស៊ីហើយគាត់ជិតស្លាប់ដោយជំងឺរាករូស ។ លោកពូ សំឌិន បានប្រាប់យើងថា មូលហេតុគាត់ជាប់គុកដោយហេតុថា សម័យ ប៉ុល ពត នៅកងពិសេស (កងចល័តយុវជន) ។ គាត់ជាប់គុកគឺដោយសារគាត់ធ្វើការថ្ងៃត្រង់ហើយគ្មានបានហូប គាត់ក៏ដើរចូលព្រៃរកបេះប្រង់ស៊ី ជួនជាបានជួបពួកវា វាចោទថាគាត់លួចស្រូវ ពួកវាចាប់ចងដៃទៅក្រោយរួចបណ្តើរទៅទីតាំងស្រុកព្រៃនប់ ចងដាក់ក្រោមគ្រែ គ្នាវាសួរថាអ្ហែងចាប់ជ្រូកព្រៃមកពីណា? ពួកវាឆ្លើយថាជ្រូកព្រៃស៊ីស្រូវ ។ ពួកវាចាប់គាត់នៅដើមឆ្នាំ១៩៧៧ ក្រោយមកគេបញ្ជូនគាត់ទៅគុកសន្តិសុខកោះខ្យង ពេលនោះហើយគាត់បានឃើញគេដឹកប្រជាជនទាំងឡានៗទៅទីនោះដែរ ។ នៅពេលដើរតាមផ្លូវម៉ោង១០យប់ គាត់បានឃើញបងគាត់ គាត់ក៏ស្រែកហៅ ពួកវាវៃគាត់៣ដំបងដួលសន្លប់ ក្រោយមកវាក៏យកម៉ូតូឌុបគាត់ដល់គុកម៉ោងប្រហែល៣ទៀបភ្លឺ ។ ពេលគាត់ចុះពីលើម៉ូតូ មានមនុស្សមកទទួលវៃខ្នោះដៃរួចរុញបញ្ចូលគុក វាវៃខ្នោះជើងទៀត រួចហើយវានិយាយថាបើអ្ហែងដុះអាចម៍នោមហៅអញ ។ នៅក្នុងគុក សំឌិន ត្រូវស្ថិតក្នុងសភាពដូចជនរងគ្រោះដទៃដែរគឺដៃត្រូវចងទៅក្រោយពាគន្លាក់ ខ្នោះជើងមានច្រវាក់ដាក់ទៀត ។ គាត់បានបង្ហាញស្លាកស្នាមនៅកជើងកដៃ ហើយបង្ហាញពីរបៀបអង្គុយ ដេក នៅក្នុងគុកឲ្យយើងថតទុកជាឯកសារ ។ អំពីទារុណកម្ម សំឌិន បានប្រាប់យើងថា ១ថ្ងៃៗសួរចម្លើយ៣ដង សួរម្តងៗវៃសន្លប់គ្មានដឹងខ្លួនទេ ទារុណកម្មព្រៃផ្សៃបំផុតគឺស្រាតខោអាវទុកតែខោមួយទេ វាហាមមិនឲ្យនិយាយច្រើន សួរត្រង់ណាឆ្លើយត្រង់ណឹង ។ គាត់ប្រាប់ថាការហូបចុកគឺបបររាវ ឯដំឡូងដាំបានគាស់ចោលដាំទៀត មិនឲ្យស៊ីទេ បើអ្នកទោសរើសពួកវាវៃងាប់ក៏មានសន្លប់ក៏មាន អ៊ីចឹងមិនហ៊ានរើសស៊ីទេ ។ ពេលហូប បបរដាក់ចានដែក ដួសម្តង៣ចានហុចឲ្យអ្នកទោសទទួលមិនទាន់ខ្វាយអស់ ឬរលាកទឹកកបបរស្រោចលើខ្លួនវេទនាខ្លោចផ្សាណាស់ ។ ក្នុងពេលជាប់គុកគាត់បានឃើញពួកវាវះពោះជនរងគ្រោះ បណ្តើរដាក់រណ្តៅ ខ្លះទៀតកាត់ក្បាល អ្នកស្លាប់ពួកវាកប់ជុំវិញដើមដូង១រណ្តៅ២នាក់ ជុំវិញដើមដូង៨នាក់ ថ្មីៗនេះប្រជាជនជីករណ្តៅក្បែរៗដើមដូងបានឃើញឆ្អឹងលលាដ៍ក្បាល៨នាក់មែន ។ លោកពូ សំឌិន បានប្រាប់យើងថា គាត់ជាប់គុកធំរយៈពេល២ខែ តមកជាប់គុកកែប្រែ៧ខែ ហើយចុងក្រោយជាប់គុកតានៃស្រុកព្រៃនប់ ។ គាត់បានរួចជីវិតដោយពួកវាដោះលែងដូច ស៊ីនឿនដែរ ។ គាត់ថា ចុងក្រោយជាគុកតានៃនេះហើយគាត់ស៊ីថ្មើមអ្នកជាប់គុកដូចគ្នា គាត់ថាមានយុវជនពីរនាក់បងប្អូនលួចរត់ចេញពីគុក រត់ទៅហើយគ្មានបបរស៊ីត្រឡប់មកគុកវិញ ពួកវាឲ្យគេវះពោះយកថ្លើមអ្នក

ទាំងពីរនោះឲ្យគាត់ស៊ី វាឲ្យឆ្នាំង១ អំបិល ម្ហូរស្លឹកថ្នឹង ។ សម្លម្ហូរថ្ងៃនេះ សំឌិន ថាគាត់ស៊ី ទាល់តែអស់ គាត់ថាគាត់ឃ្លានពេក ។

-ប្រភេទជនរងគ្រោះធ្លាប់ជាប់គុកជាមួយគាត់ គឺមានមនុស្សចាស់ យុវជន យុវតី កុមារ ។ មនុស្សចាស់វាសម្លាប់មុនគេ ។ វាថា ចាស់ៗស្នូរក្បាលដុះស្លែពិបាកអប់រំណាស់ មិនអាចកែប្រែបានទេ ។

-សាក្សីជនរងគ្រោះ សំឌិន បាននាំយើងទៅចន្លុលរណ្តៅសម្លាប់នៅទីតាំងកោះខ្យង បង្ហាញគុក សន្តិសុខ និងដេកធ្វើសលនាឲ្យក្រុមយើងថត ។ សាក្សី សំឌិន បានសម្តែងកំហឹងថា គាត់មិនអាចភ្លេច អស់មួយជីវិត ។ ចុងក្រោយបំផុតនៅគុកតានៃ ស្រុកព្រៃនប់ គាត់បានរួចដូចសាក្សី ស៊ីនឿន ដែរ ។ ជាចុងក្រោយ យើងបានសួរបញ្ជាក់បន្ថែមទៀតអំពីទារុណកម្មពេលសួរចម្លើយ គាត់ប្រាប់ថា ពួកវាយកអាវ ភ្លៀងរុំមុខ ៥នាទីសន្ទប់ដោះចេញ វិធីសួរប្រើរំពាត់ ព្រនង់ផ្តៅ ឆក់ខ្សែភ្លើង ។ ដាក់ស្នែងពេលពួកវា បាត់ពូថៅ អ្នកទោសម្នាក់លាក់ទុកក្រោមដំណេក ដាក់លាមកពីលើ វារកឃើញវាយកពូថៅនោះកាប់ អ្នកទោសនោះចំបំពង់កស្លាប់មួយរំពេច ។ យើងឲ្យ សំឌិន ស្តាប់កាសែ្សតសំឡេង និងបញ្ជាក់ថាពិតជា សំឡេងរបស់គាត់មែន ។

(សម្តីសាក្សី សំឌិន គឺយើងបានថតកាសែ្សតទុកជាឯកសារហើយ

យើងកត់ត្រាបានប៉ុណ្ណឹង ។)

សម្ភាសន៍សាក្សីទី៣ គាំ យោ ១គានឃ្វុប

លោកតា គាំ យោ អាយុ៥៧ឆ្នាំ ជាជនរងគ្រោះធ្លាប់ជាប់គុកនៅកោះខ្យងរយៈពេល៣ឆ្នាំ ។ លោកតាមានស្រុកកំណើតនៅភូមិអូរតូច ឃុំកំពត ស្រុកកំពត ខេត្តកំពត ។ មុនសម័យ ប៉ុល ពត មានប្រពន្ធនៅភូមិអណ្តូងថ្ម ឃុំសំរុង ខណ្ឌព្រៃនប់ ។ សម័យ ប៉ុល ពត នៅភូមិអណ្តូងថ្ម ឃុំសំរុង ខណ្ឌព្រៃនប់ ត្រូវពួកខ្មែរក្រហមចាប់ខ្លួនដោយចោទថាស៊ីដូង្ស្វាយ ព្រោះឃើញគាត់នៅក្នុងចម្ការស្វាយ គេមកឃើញកំពុងតែបេះស្វាយស៊ី ។ ក្រៅពីចោទថា ស៊ីស្វាយហើយគេនៅចោទប្រកាន់គាត់ទៀតថាចូល ដៃជើងជាមួយខ្មែរស ។ អ្នកចាប់គាត់ឈ្មោះ មិត និងពួកគេជាច្រើនទៀតលើកកាំភ្លើងភ្ជង់គាត់ រួចចងដៃ គាត់ជាប់នឹងបង្គោលទុកសិន ។ ពួកវាថាចាំឲ្យសហករណ៍មកយកទៅវិញ (ដោះស្រាយ) ។ ម៉ោង៦ល្ងាច គេដឹកគាត់យកទៅអូរត្រាច ។ គេចាប់គាត់ពីឆ្នាំ១៩៧៦ យកទៅគុកកោះខ្យងរហូតដល់ឆ្នាំ១៩៧៨ ពី១៩៧៨-៧៩មួយឆ្នាំទៀត គឺជាប់រយៈពេល៣ឆ្នាំ ។

សកម្មភាពពួកគុកសន្តិសុខខ្មែរក្រហមនៅកោះខ្យងបានធ្វើទារុណកម្ម ដាក់ខ្នោះជើង ដៃ ហូបចុក ធ្វើការងារ ដូចសាក្សីទី១ ទី២ដែរ មិនខុសគ្នាទេ ។ គាត់មានស្នាកស្នាមនៅកជើង គឺគាត់ជាប់ខ្នោះជើង ។ គេសួរចម្លើយគាត់ គាត់ឆ្លើយថាស៊ីផ្លែស្វាយ គេក៏ចោទគាត់ថាដើរទាក់ទងខ្មែរស ។ នៅទីនោះគាត់បានឃើញគុកខ្វះងងឹតទាំងយប់ទាំងថ្ងៃ គុកងងឹតគាត់បានឃើញផ្ទាល់ភ្នែកនូវទារុណកម្ម វាយ ទាត់ ធាក់ នៅនឹងមុខគាត់ជារៀងរាល់ថ្ងៃ ។ ដៃជើងគាត់ជាប់ខ្នោះដូចគេដែរ ។ ប្រភេទជនរងគ្រោះគាត់ដឹងថា នៅទីនោះជនរងគ្រោះមួយចំនួនជាប់គុក មួយចំនួនទៀតយកមកសួរចម្លើយ រួចហើយសម្លាប់ចោលតែម្តងមិនដាក់គុកទេ ។ មួយថ្ងៃៗគេដឹក ៣-៤ ទៅ ៥ឡាន យកមកទីនេះជារៀងរាល់ថ្ងៃកាលពីឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ។ អ្នកនៅក្នុងគុកត្រូវយកចេញសម្លាប់ រួចបញ្ចូលថែមជារៀងរាល់ថ្ងៃ ។ ជនរងគ្រោះយកពីកោះកុង ស្រែអំបិល និងកំពង់សោម ។ គាត់ប៉ាន់ស្មានថាជនរងគ្រោះត្រូវបានសម្លាប់នៅទីនោះប្រហែលកន្លះលាន គឺ ៥០០,០០០នាក់ ( Site form 50,000 ) គឺត្រូវមែន ។ យើងគិតថាក្នុងបរិវេណគុកសន្តិសុខ២គីឡូម៉ែត្រ ៤ជ្រុង ហើយនៅកោះក្របីមួយទៀតសម្លាប់ពេញទាំងអស់ ។ ប្រជាជននៅទីនោះរាយការណ៍ថា គាត់ជីក គាស់ដីដាំដុះ កន្លែងណាក៏ប៉ះឆ្អឹងដែរ ឯសាក្សីចង្អុលបង្ហាញរណ្តៅដែលរលុបបាត់អស់ដោយសារប្រជាជនគេ កាប់ឆ្ការរុនរានទន្ទ្រានដីដាំដំណាំអស់ ។ ឯកន្លែងចុងជើងភ្នំខាងកើតយើងមិនបានទៅដល់ សុទ្ធតែព្រៃ អាចមានមីន ឯកោះក្របីមានមីនផ្ទុះងាប់ក្របីជាហូរហែរ ។ សាក្សី គាំ យោ បានរស់រានមានជីវិតដោយសារគាត់សកម្មការងារ គេឲ្យធ្វើអ្វីចេះតែខំធ្វើមិនមាត់អ្វីសោះទេ ។ គាត់មានបងប្អូន៩នាក់ត្រូវស្លាប់ក្នុងរបប ប៉ុល ពត ទាំងអស់ ។ យើងសួរពីកំហឹងរបស់គាត់ គាត់ថាឆ្អែតចិត្តហើយ គាត់ស្រក់ទឹកភ្នែក ។ (យើងបានសួរបញ្ជាក់ថាសំឡេងសម្ភាសន៍តើជាសំឡេងគាត់មែនទេ? គាត់ឆ្លើយថាមែន ។ ក្រៅពីនេះបទសម្ភាសន៍ទាំងស្រុងយើងមានថតទុកក្នុងកាសែ្សតហើយ) ។

នៅម៉ោង ១២:១៥នាទី យើងទៅដល់កោះខ្យង ជាទីតាំងគុក សន្តិសុខ កន្លែងសម្លាប់ មានទំហំ ២គីឡូម៉ែត្រ៤ជ្រុង យើងរួមដំណើរដោយពួកស៊ីម៉ាក់ ក្រុមថតវីឌ្យូភាពយន្ត កងរាជអាវុធហត្ថជាតិ នគរបាលប្រចាំប៉ុស្តិ៍ឃុំអូរជ្រៅ មេឃុំ និងសាក្សីទាំងអស់ ។

ពេលទៅដល់ទីនោះ យើងសម្ភាសន៍សាក្សីរួចឲ្យគាត់នាំយើងទៅចង្អុលទីតាំងគុកធំ គុកកែប្រែ និងទីតាំងសម្លាប់ ។ កន្លែងគុកធំទី១មានផ្ទះប្រជាជនសង់ពីលើ ទី២មានផ្ទះប្រជាជន ទី៣ក៏មានផ្ទះនៅពីលើអស់ហើយ តែមានដើមដូងជាសម្គាល់ ដើមដូងទាំងនេះខ្ពស់ៗតាំងពីពេលមុនៗមក ។ ឯកន្លែងពួកវាគឺនៅលើកំពូលភ្នំ ជើងភ្នំកោះខ្យង ហើយនៅក្បែរនោះមានឃ្លាំងគ្រាប់រំសេវពួកទ័ពមួយយ៉ាងធំនៅជាយភ្នំ

កោះខ្យងដែរ ។ ទ័ពនៅជុំវិញគុកសន្តិសុខ ឯកន្លែងគណៈស្រុក ពួកសន្តិសុខនៅជាមួយក្បែរៗគុកដែរ ។ គណៈស្រុកឈ្មោះ អាផល បាត់ខ្លួន ។ មេសន្តិសុខឈ្មោះ អាសឿន ទាំងពីរ នាក់នេះសាក្សី ឥន្ទ ឌីន និង គាំ យោ បានប្រាប់យើង ។ យើងនិងសាក្សីក្រុមថតខ្សែភាពយន្តបានកត់ត្រានិងថតសម្តីសាក្សី ចុចម៉ាស៊ីន អក្ស កំណត់ទីតាំងគុក សន្តិសុខ កន្លែងសម្លាប់ និងកន្លែងឃុំងគ្រាប់ និងថតទីកន្លែងដែលពួកមេខ្មែរក្រហម ស្នាក់នៅ ។ នៅលើកំពូលភ្នំមានសាលាប្រជុំមួយនៅទីនោះ សាក្សីបានឲ្យយើងដឹងថាជាទីតាំងទ័ពកងពល ។ គុកសន្តិសុខនៅទីនេះធំជាងគេទូទាំងក្រុងព្រះសីហនុ ។

ទីតាំងកោះខ្យងស្ថិតក្នុងភូមិកោះខ្យង ឃុំអូរជ្រៅ ខណ្ឌព្រៃនប់ ក្រុមព្រះសីហនុ ចម្ងាយ៧គីឡូម៉ែត្រ ពីផ្លូវជាតិលេខ៤ ទីក្រុងព្រះសីហនុចម្ងាយ៤៧គីឡូម៉ែត្រ ។

យើងបានឲ្យសាក្សីទាំងអស់ចង្អុលគុកទាំងអស់ គឺគុកមនុស្សចាស់ៗដោយឡែក គុកកុមារតូចៗ ដោយឡែក គុកស្រីដោយឡែក គុកយុវជន-យុវតីដោយឡែកៗពីគ្នា នៅទីនោះជនរងគ្រោះខុសពីបណ្តា ទីតាំងខេត្តដទៃ នៅកន្លែងផ្សេងគ្មានកុមារអាយុ១០-១២-១៥ឆ្នាំជាប់គុកទេ ឯកន្លែងនេះគឺមានកុមារតូចៗ ហើយកុមារនេះហើយពួកវះពោះយកថ្លើមស៊ី និងយកប្រមាត់ ។ នៅខាងលិចគុកចម្ងាយប្រហែល៥០០ ម៉ែត្រ មានទីតាំងសម្លាប់មួយ មានដើមឈើមួយដើម នៅទីនោះពួកវាបានយកប្រមាត់អ្នកស្លាប់ប្រហែលជា ៥០០ ទៅ ១០០០ ចង់ព្យួរហាលថ្ងៃ គឺដោតជាខ្សែៗ មួយខ្សែប្រហែលពី៥០ ទៅ១០០ប្រមាត់ គាត់ឃើញ ។ ដូច្នេះអាចសន្និដ្ឋានថា មានអ្នកស្លាប់ច្រើនដូចសាក្សីខ្លះថាកន្ទះលាន ឬយ៉ាងហោចណាស់ គាត់ថាប្រាំម៉ឺនៗ តាមសាក្សីឲ្យយើងដឹងថា មានកម្មាភិបាលខ្មែរក្រហម ទ័ព ក៏ជាប់គុកនៅទីនោះដែរ ។

សាក្សីទី៥ ឡេង យាន អាយុ៤៤ឆ្នាំ យើងបានជួបគាត់នៅកោះខ្យង គាត់មានស្រុកកំណើតនៅ ឃុំបឹង តាព្រហ្ម សព្វថ្ងៃនេះនៅក្នុងខណ្ឌព្រៃនប់ ។ កាលពីសម័យ ប៉ុល ពត ជាគុកជាមួយសាក្សីទាំង ៤នាក់មុនដែរ ។ គាត់និងសាក្សីបាននាំយើងទៅប្រាប់កន្លែងសំខាន់ៗ មានគុកនៅកោះខ្យងនិងកន្លែងសម្លាប់ ។ គុកមានពីរប្រភេទៈ ប្រភេទទី១គុកធំ គុកធ្ងន់ និងប្រភេទទី២គុកកែប្រែ ប៉ុន្តែដាក់អ្នកទោសដោយឡែកៗ ពីគ្នា ក្មេង ចាស់ យុវជន នារី មិនដាក់ជាមួយគ្នាទេ ។ សាក្សីនេះបានចាំថា ដើមឈើហាលប្រមាត់គឺដើម **ស្វាច់ដោម** ។ ហើយម្យ៉ាងទៀតគាត់បានដឹងច្បាស់ថា មួយយប់ៗពួកពេជ្ឈឃាតសន្តិសុខយកជនរងគ្រោះ ៥ទៅ១០នាក់រាល់យប់ ។ បើគេយកពេលយប់គ្មានរស់ទេ យកចេញពីគុកបាត់រហូតមិនឃើញមកវិញទេ ។ ឯពួកក្មេងអាយុ ៧-៨ឆ្នាំ ១០ឆ្នាំ អត់អាហារ លួចដើរបេះស្លឹកទន្រ្ទានខេត្រស៊ី វាចាប់ចងបណ្តើរម្តង ១០-១២នាក់ យកទៅវៃដាក់គុកសួរចម្លើយ រួចវះពោះយកថ្លើមតែម្តង មុនទម្លាក់រណ្តៅ វេទនាខ្លោចផ្សា និងព្រៃផ្សៃបំផុត គាត់ឃើញផ្ទាល់ភ្នែក ។ គាត់មានកូន២នាក់ អត់បាយស្លាប់ជំនាន់នោះ គាត់នឹកឃើញ

មិនភ្លេចទេ ។ គាត់បានសន្និដ្ឋានថា អ្នកស្លាប់នៅទីនោះមានច្រើននៅក្រោមគល់ដូង គល់ឈើ គល់ការស្វា ។ល។ ហើយអដ្ឋិធាតុគ្មានបានយកទៅទុកទេ យកតិចតួចប៉ុន្តែដុតចោលអស់ហើយ ។

ម្យ៉ាងទៀត នៅទីនោះយើងបានជួបលោកតាម្នាក់កំបុតដៃ ភ្នែកឡើងបាយ ដោយសារត្រូវមីនខ្មែរក្រហមដាក់នៅជាយភ្នំកោះខ្យង ក្រោយរំដោះគាត់បានគាស់រំលើងដើមឈើ ចាំងស្មៅយកដីនៅក្បែរឃ្លាំងគ្រាប់របស់ខ្មែរក្រហមដើម្បីដាំដំណាំ ក៏ប៉ះមីន ។ គាត់ថាមិនលើកោះខ្យងនេះមានមែនពិត ប៉ុន្តែបានផ្ទុះអស់ខ្លះហើយ គាត់មិនដឹងថានៅមានទៀតឬក៏អត់ទេ ប៉ុន្តែជាងម្ភៃឆ្នាំនេះគេដើរពេញទាំងអស់មិនឃើញអីទេ ។ លោកតាឈ្មោះ យូ លីអេង អាយុ៦៧ឆ្នាំ សព្វថ្ងៃនៅភូមិកោះខ្យង ឃុំអូរជ្រៅ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។

ម៉ោង ១២ ខ្វះ ១៥នាទី ក្រុមស៊ីម៉ាក់បានរាវមីននិងដាក់សញ្ញាតាមផ្លូវរួច យើងត្រូវឡើងលើកំពូលភ្នំ កោះខ្យង ក្រុមយើង ក្រុមស៊ីម៉ាក់ ដើរមុនក្រុមថតខ្សែភាពយន្តឯកសារ ថតពីមុខរហូតដល់កំពូលភ្នំ ។ យើងបានសម្ភាសសាក្សីម្នងទៀតគឺលោកតា ឥន្ទ ឌីន អាយុ ៥១ឆ្នាំ គាត់មានស្រុកកំណើតជាមួយសាក្សី គាំ យោ ដែរ ។ ខ្លឹមសារសម្ភាសន៍ដូចគ្នានឹងសាក្សីទាំងអស់ រាល់សកម្មភាពបានឃើញផ្ទាល់ដឹង ឮ និងទទួលទារុណកម្មដូចសាក្សីដទៃដែរ ។ ខ្លឹមសារមាននៅក្នុងកាសែ្សតស្រាប់ទុកជាឯកសារ ។ ឯក្រុមថតខ្សែភាពយន្តឯកសារ គេថតសកម្មភាពពួកយើងដូចទីតាំងដទៃ សាក្សីដទៃៗដែរ ។

ទីបំផុត ក្រុមថតខ្សែភាពយន្តឯកសារបានថតសម្ភាសន៍លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារ និងលោក ផាត កុសល នាយករងទី១ នៅលើកំពូលភ្នំកោះខ្យង ។ យើងចប់សព្វគ្រប់នៅម៉ោង ១៤:៣០នាទី គឺម៉ោង ២កន្លះ រសៀលថ្ងៃទី ១៨-២-២០០០ នោះដោយសុវត្ថិភាព ។ ក្រុមយើងព្រមទាំងកងរាជអាវុធហត្ថ និងសាក្សី បានទទួលទានបាយនៅខណ្ឌព្រៃនប់ចប់នៅម៉ោង១៥:៣០នាទី ។

<u>សេចក្តីសន្និដ្ឋាន និងវាយតម្លៃការងារ</u>

តាមរយៈការចុះស្រាវជ្រាវនៅទីតាំងកោះខ្យង ជាទីតាំងប្រល័យពូជសាសន៍ ស្ថិតនៅក្នុងភូមិកោះខ្យង ឃុំ អូរជ្រៅ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ លើកទី១នេះជាលើកពិសេស ដោយយើងបាននាំក្រុមថតភាពយន្តឯកសារប្រទេសអឺរ៉ុប បែលហ្ស៊ិក អៀរឡង់ បារាំង ទៅជាមួយ ។ ការស្រាវជ្រាវថតនៅលើកនេះយើងទទួលបានលទ្ធផលគួរជាទីពេញចិត្ត ហើយយើងបានកត់សម្គាល់ឃើញចំណុចលេចធ្លោជាបទពិសោធន៍ដូចតទៅ៖

ក-ការទំនាក់ទំនងជាមួយអាជ្ញាធរដែនដីនៅគ្រប់លំដាប់ថ្នាក់តាំងពីថ្នាក់លើរហូតថ្នាក់ក្រោម សាក្សី បានល្អប្រសើរ គឺគេបានគាំទ្រយើងនិងសហការជួយយើងគ្រប់មធ្យោបាយ បង្កលក្ខណៈងាយស្រួល ទាំងពត៌មាន សន្តិសុខ សាក្សី បានល្អប្រសើរ ។

ខ-ចំពោះកម្លាំងការពារយើងមានការងាយស្រួលថែមទាំងមានភាពសមស្រប ជាការលើកទឹកចិត្ត កិត្តិយសលើសទីណាៗទាំងអស់ សាមគ្គី សហការដោយស្មោះអស់ពីចិត្ត គ្មានបញ្ហាអ្វីសោះឡើយ ។

គ-ក្រុមស្រាវជ្រាវមជ្ឈមណ្ឌលយើង និងក្រុមថតភាពយន្ត មានភាពស្និទ្ធស្នាល យោគយល់ និងសាមគ្គី សហការការងារបានល្អប្រសើរ សម្រេចបានតាមកម្មវិធីការងារដែលបានគ្រោងទុក ជាមុន និងស្រាវជ្រាវបន្ថែមយ៉ាងល្អប្រសើរ ។

ឃ-លទ្ធផលទាំងអស់នេះហើយដោយសារតែយើងមានគោលការណ៍និងការគាំទ្រពីរាជរដ្ឋាភិបាល កម្ពុជា និងការគាំទ្រពីថ្នាក់ដឹកនាំកំពូលៗនៃរាជរដ្ឋាភិបាល ព្រមទាំងអាជ្ញាធរដែនដី ហើយក្នុងនោះ ទៀតសោត ក្រោមការដឹកនាំដោយឈ្លាសវៃរបស់លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានខិតខំប្រឹងប្រែង និងចុះជួយដោយផ្ទាល់នៅទីតាំងនោះ ធ្វើឲ្យកិច្ចការសម្រេចបានជោគ ជ័យល្អប្រសើរ ។

ង- ប៉ុន្តែយើងនៅខ្វះចន្លោះខ្វះដែរ ដោយទីតាំងនោះសម្បូណ៌ជនរងគ្រោះនៅរស់ច្រើន តែយើង ជួបគាត់មិនអស់ យើងរកជនដៃដល់នៅរស់មិនឃើញ យើងទៅកាន់គុកសន្តិសុខតានៃទី២មិនបាន ដល់ ខ្វះអដ្ឋិធាតុជាភស្តុតាង មានអ្នកគាស់យកមកដុតចោល ។ ប៉ុន្តែដោយពេលវេលាយើង មិនបានចុះទៅស្រាវជ្រាវកត់ត្រាអំពីអ្នកទាំងនោះ ប៉ុន្តែលើកទី១យើងបានខិតខំរហូតដល់ម៉ោង១៥ (ម៉ោង៣រសៀល) ទើបហូបបាយ ពោលគឺព្រឹកនោះខិតខំអស់ពីកម្លាំងកាយចិត្តរបស់យើង ។ យើងសង្ឃឹមថា នឹងអាចចុះទៅទីនោះជាលើកទី២ទៀត ដើម្បីស្រាវជ្រាវឲ្យបានច្បាស់គ្រប់ជ្រុង ជ្រោយ ឲ្យកាន់តែល្អជាងនេះទៅទៀត ។

ថ្ងៃទី ១៩-២-២០០០ ក្រុមស្រាវជ្រាវយើងបានត្រឡប់មកភ្នំពេញវិញដោយសុវត្ថិភាព ។

ភ្នំពេញ ថ្ងៃទី **27-2-2000**

អ្នកចុះស្រាវជ្រាវដោយផ្ទាល់

អ្នកសរសេររបាយការណ៍

មានភ្ជាប់មកជាមួយនូវៈ

- ឯកសារបង្រ្កង
- រូបថតសាក្សី
- រូបថតទីតាំងគុក សន្តិសុខ
- រូបទីតាំងសម្លាប់

ស៊ិន ឃិន